ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ០៦ អយក.សព្វត

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី
## ការបន្តដំណើរការកម្មវិធីសាលារៀនជំនាន់ថ្មី និងការលុបចោលកម្មវិធីសិក្សាទំនើប

ក្រសួងអប់រំ យុវជន និងកីឡា សូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា៖ ក្នុងពេលថ្មីៗ នេះមានការយល់ច្រឡំថា ក្រសួងនឹងលុបចោលកម្មវិធីសាលារៀនជំនាន់ថ្មី។ ក្រសួងសូមបញ្ជាក់ថា ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល ក្រសួងនឹងនៅតែបន្តអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មីនេះតទៅទៀត ហើយថែមទាំងបន្តវិនិយោគបន្ថែមទៀត ដើម្បីឱ្យដំណើរការ ចំនួន ១៤ កន្លែង នៅទូទាំងប្រទេសក្នុងឆ្នាំសិក្សា ២០២៤-២០២៥ នេះ។

សាលារៀនជំនាន់ថ្មី គឺជាគ្រឹះស្ថានសិក្សាសាធារណៈ ស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលផ្ដល់ជាគំរូអភិបាលកិច្ចល្អ ស្ដង់ដាវិជ្ជាជីវៈខ្ពស់ និងផ្ដល់ការអប់រំមានគុណភាពខ្ពស់។ សាលារៀនជំនាន់ថ្មីផ្តោតលើការអនុវត្តកម្មវិធីសិក្សាពេញលេញ ផ្ដល់ឱកាសសិក្សាពេញមួយថ្ងៃ អនុវត្តវិធីសាស្ត្របង្រៀនទំនើបតាមបែបរិះរក ការដោះស្រាយបញ្ហា និងការសិក្សាតាមបែបគម្រោង កម្មវិធីបច្ចេកវិទ្យា ដែលបណ្ដុះទាំងវិជ្ជាសម្បទា បំណិនសតវត្សទី២១ ជាពិសេសបំណិនសហការ ត្រិះរិះពិចារណា ទំនាក់ទំនង លើកកម្ពស់ស្វ័យសិក្សា ការស្រាវជ្រាវរបស់សិស្ស និងការរៀបចំពិព័រណ៌ស្នាដៃសិស្ស រួមទាំងការអប់រំសីលធម៌ និងចរិយាធម៌ ដែលឆ្លើយតបទៅនឹងយុគសម័យបច្ចេកវិទ្យាឌីជីថល។

សាលារៀនជំនាន់ថ្មីបានបំពាក់សម្ភារៈ និងបរិក្ខាររៀន និងបង្រៀនទំនើប និងរៀបចំបណ្ណាល័យសតវត្សទី២១ អាហារដ្ឋាន បន្ទប់ពិសោធន៍ ដែលអាចឱ្យគ្រូបង្រៀន និងសិស្សប្រើប្រាស់បច្ចេកវិទ្យា និងភាសាបរទេស។

ដោយផ្អែកលើបទពិសោធន៍ជោគជ័យប្រកបដោយផ្លែផ្កា ក្រសួងនឹងអនុវត្តគោលការណ៍ ដូចខាងក្រោម សម្រាប់ការបន្តអភិវឌ្ឍសាលារៀនជំនាន់ថ្មី៖

១. សាលារៀនជំនាន់ថ្មី ដែលមានស្រាប់នឹងបន្តដំណើរ ដោយរាជរដ្ឋាភិបាលផ្ដល់ថវិកាបន្ថែម ដើម្បីជំនួសការបង់វិភាគទានជាកាតព្វកិច្ចរបស់មាតាបិតា ដើម្បីធានាការអប់រំប្រកបដោយសមធម៌។ សាលារៀននៅតែអាចបន្តទទួលវិភាគទានពីសប្បុរសជន និងមាតាបិតា តាមគោលការណ៍ស្ម័គ្រចិត្ត។

២. ក្រសួងនឹងពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មីបន្ថែមទៀតតាមលទ្ធភាពថវិកា ដើម្បីផ្ដល់ឱកាសដល់សិស្សក្នុងការទទួលការអប់រំប្រកបដោយគុណភាពខ្ពស់ សមធម៌ និងគ្មានការរើសអើង។

ជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡានឹងលុបចោលនូវការអនុវត្ត «កម្មវិធីសិក្សាទំនើប» ដែលបានអនុវត្តដោយក្រុមហ៊ុនឯកជននៅតាមសាលាបឋមសិក្សា ចំនួន ១៨ មានសិស្ស ចំនួន ៤ ៣០០ នាក់ កំពុងសិក្សារៀនសូត្រ ក្នុងរូបភាពជាកិច្ចសហការរវាងផ្នែកឯកជនជាមួយនឹងសាលារៀនផ្ទាល់ និងមិនស្ថិតក្រោមការ

គ្រប់គ្រងរបស់ក្រសួង។ កម្មវិធីនេះអនុវត្តខុសពីនីតិវិធីនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងបង្កើតឱ្យមានការរើសអើងរវាងសិស្ស ដែលកំពុងសិក្សាក្នុងថ្នាក់តែមួយ ដែលមានលទ្ធភាពបង់ប្រាក់ និងសិស្សដែលគ្មានលទ្ធភាពបង់ប្រាក់ ព្រមទាំងបង្កើតឱ្យមានស្តង់ដាពីរក្នុងសាលារៀនតែមួយ។

ដើម្បីបន្តផ្តល់ការអប់រំប្រកបដោយគុណភាពនៅតាមសាលាបឋមសិក្សាខាងលើ ក្រសួងកំពុងស្វែងរកថវិកា ដើម្បីទទួលយក «កម្មវិធីសិក្សាទំនើប» និងផ្តល់ឱកាសដល់សិស្ស ១០០ ភាគរយ ក្នុងសាលាសិក្សារៀនសូត្រតែម្តង។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន ។

ថ្ងៃ សុក្រ ២ កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥